# លទ្ធផលស្ទង់មតិបុគ្គលិក អ.វ.ត.ក

## មូលដ្ឋាននៃការសិក្សារបស់ អ.វ.ត.ក ស្តីពីការយល់ដឹងយេនឌ័រក្នុងដំណើរការយុត្តិធម៌អន្តរកាលនៅប្រទេសកម្ពុជា

## អង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អង្គភាពគាំពារជនរងគ្រោះបានបង្កើតការស្ទង់មតិតាមវិធីសាស្ត្រចន្លោះ ស្តីអំពីបុគ្គលិករបស់ អ.វ.ត.ក ចំនួន៥០នាក់ ចាប់ពីថ្ងៃទី ២០ ខែកុម្ភៈ ដល់ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១២។ អ្នកផ្តល់ចម្លើយទទួលបានតារាងសំណួរជាលាយលក្ខណ៍អក្សរ ដែលមានទាំងភាសាអង់គ្លេស និងភាសាខ្មែរ។ អ្នកផ្តល់ចម្លើយត្រូវបានស្នើឲ្យឆ្លើយសំណួរច្រើនតាមតែអាចធ្វើបាន តាមសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនក្នុងនាមជាសមាជិកបុគ្គលិករបស់អ.វ.ត.ក។ កម្រិតនៃការស្ទង់មតិត្រូវបានផ្តល់សម្រាប់ចម្លើយនានា ដោយមានលេខ “៥” បង្ហាញថាយល់ស្របយ៉ាងខ្លាំង ហើយលេខ “១” បង្ហាញថាមិនយល់ស្របយ៉ាងខ្លាំង អាស្រ័យតាមចំណេះដឹងបច្ចុប្បន្នរបស់ អ្នកផ្តល់ចម្លើយ។ ក.“0” បង្ហាញថា “ខ្ញុំមិនដឹង”។ គ្រប់ចម្លើយទាំងអស់ត្រូវបានរក្សាជាការសម្ងាត់ និងអនាមិក។

ក្នុងចំណោមតារាងសំណួរស្ទង់មតិទាំង៥០ ដែលបានបំពេញរួចជាស្រេចហើយនោះ គេទទួលបានចំនួន ២១ ជាភាសាអង់គ្លេស ហើយចំនួន ២៩ មានទាំងជាភាសាខ្មែរ និងជាអង់គ្លេស។ ការសម្គាល់មួយលើវិធីសាស្ត្រ នៅត្រង់ការបង្កើតការស្ទង់មតិសាជាថ្មីនាពេលអនាគត មានអ្នកផ្តល់ចម្លើយមួយចំនួនបានរាយការណ៍ថា ភាសាប្រើក្នុងតារាងស្ទង់មតិមានភាពស្មុគស្មាញពិបាកយល់។ ចំណុចមួយទៀត ត្រង់សំណួរលេខ “១0” គេគួរតែសរសេរសាឡើងវិញ ដោយផ្តោតទៅលើអសមភាពប្រាក់ខែយេនឌ័រ ឬ ក៏ត្រូវលុបចោលសំណួរនោះ ទាំងស្រុងតែម្តង។

តារាងសំណួរស្ទង់មតិត្រូវបានបង្ហាញតាមរយៈការិយាល័យ ឬ អង្គភាពដូចខាងក្រោម៖

| ចម្លើយពីការិយាល័យ ឬ អង្គភាពនៃអ.វ.ត.ក |
|---|
| អង្គភាពបកប្រែ |
| ផ្នែកគ្រប់គ្រងតុលាការ |
| ផ្នែកគាំពារការការពារក្តី |
| ផ្នែកសេវាព័ត៌មានវិទ្យា |

មូលដ្ឋានស្ទង់មតិបុគ្គលិករបស់ អ.វ.ត.ក

Original EN: 00831644-00831650

| |
|---|
| ផ្នែកថវិកា និងហិរញ្ញវត្ថុ<br>ផ្នែកសេវាទូទៅ<br>អង្គភាពគាំពារសាក្សី និងអ្នកជំនាញ<br>ផ្នែកធនធានមនុស្ស<br>ផ្នែករដ្ឋបាល<br>អង្គភាពគាំពារជនរងគ្រោះ<br>ផ្នែកកិច្ចការសាធារណៈ<br>ផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី |

ចម្លើយត្រូវបានដាក់បង្ហាញនៅខាងក្រោម។ តាមការសង្កេប ភាគរយកើនស្មើតែស្មើនឹងចំនួនដ៏ខ្ពស់បំផុត។

| **ក. កង្វល់របស់ស្ត្រី និងបុរស គោល ការណ៍រួម និង គម្រោងនានា** | **លទ្ធផល** |
|---|---|
| ១. ស្ត្រីត្រូវបានតំណាងក្នុងចំនួនស្មើនឹងចំនួនបុរស នៅគ្រប់កម្រិតនៃការធ្វើសេចក្តីសម្រេចលើគ្រប់ទិដ្ឋភាពប្រតិបត្តិការរបស់ អ.វ.ត.ក។ | ចម្លើយសរុប: ៥០<br>៥= យល់ស្របយ៉ាងខ្លាំង (១៣) (២៦%)<br>៤= យល់ស្រប (២៥) (៥០%)<br>៣= យល់ស្របបន្តិចបន្តួច (៦) (១២%)<br>២ = មិនយល់ស្រប (៥) (១០%)<br>១ = មិនយល់ស្របយ៉ាងខ្លាំង (0)<br>0 = ខ្ញុំមិនដឹង (១) (១%)<br>គ្មានចម្លើយ (0)<br>ភាគរយច្រើនលើសលុប (៨៨%) នៃនិយោជិត ដែលជ្រើសរើសជាតំណាងឆ្លើយថាស្ត្រីនិងបុរស ដែលគេជ្រើសរើសជាតំណាងមានចំនួនស្មើនឹង ចំនួនបុរស ដោយ រួមបញ្ចូលទាំងកម្រិតនៃការធ្វើ ការសម្រេចនៅគ្រប់ទិដ្ឋភាពទាំងអស់របស់ អ.វ.ត.ក។ |
| **ខ. សកម្មភាពជាក់លាក់ទាំងឡាយដែលបានអនុ** | **លទ្ធផល** |

| វគ្គ គឺផ្តោតទៅលើការផ្តល់អំណាចដល់ស្ត្រី | |
|---|---|
| ២. ក្រុមស្ត្រីជាអ្នកចូលរួម និងដៃគូទាំងឡាយ ទទួលឥទ្ធិពលតាមរយៈការចូលរួមផ្ទាល់ ឬ តាមរយៈការបង្កើតការប្រឹក្សាយោបល់ការអនុវត្ត ការឃ្លាំមើល និងការវាយតម្លៃលើកម្មវិធីនានា | ចម្លើយសរុប: ៥០<br>៥= យល់ស្របយ៉ាងខ្លាំង (៨) (១៦%)<br>៤= យល់ស្រប (៣៣) (៦៦%)<br>៣= យល់ស្របបន្តិចបន្តួច (៤) (៨%)<br>២ = មិនយល់ស្រប (៤) (៨%)<br>១ = មិនយល់ស្របយ៉ាងខ្លាំង (០)<br>០ = ខ្ញុំមិនដឹង (១)<br>គ្មានចម្លើយ (០)<br>ក្នុងចំណោមចម្លើយទាំង៥០មានភាគរយលើសលុប ចំនួន (៩០%) ចាប់ពីចម្លើយ *យល់ស្របយ៉ាងខ្លាំង* មកត្រឹម ចម្លើយ *យល់ស្របបន្តិចបន្តួច* ដោយលើកថា ក្រុមស្ត្រីជាអ្នកចូលរួម និងដៃគូទាំងឡាយ មានឥទ្ធិពលតាមរយៈការបង្កើត ការអនុវត្ត ការឃ្លាំមើល និងការវាយតម្លៃលើកម្មវិធីនានា ។ |
| **គ. អាណត្តិនៃស្ថាប័ន រួមបញ្ចូលទាំងបទឧក្រិដ្ឋប្រឆាំង នឹងស្ត្រីត្រូវចាត់ទុកជាបញ្ហាចម្បង** | **លទ្ធផល** |
| ៣. ការយល់ដឹងយ៉ាងទូលំទូលាយនៅក្នុង អ.វ.ត.ក អំពីមាត្រដ្ឋានអន្តរជាតិពាក់ព័ន្ធទៅនឹងបញ្ហា ការរើសអើង ផ្នែកយេនឌ័រ និងហិង្សា ផ្លូវភេទ នៅក្នុងស្ថានភាពមានជម្លោះ ហើយរួមបញ្ចូលទាំង CEDAW, UN SCR 1325, UN SCR 1820, UN SCR 1888, UN SCR 1889, UN SCR 1889 និង UN SCR 1960 ក្នុងចំណោមបញ្ហា ផ្សេងៗទៀត។ | ចម្លើយសរុប: ៤៩<br>៥= យល់ស្របយ៉ាងខ្លាំង (៩) (១៨%)<br>៤= យល់ស្រប (១៨) (៣៧%)<br>៣= យល់ស្របបន្តិចបន្តួច (៨) (១៦%)<br>២ = មិនយល់ស្រប (២) (៤%)<br>១ = មិនយល់ស្របយ៉ាងខ្លាំង (០)<br>០ = ខ្ញុំមិនដឹង (១២) (២៤%)<br>គ្មានចម្លើយ (១)<br>ក្នុងចំណោមនិយោជិត ដែលបានជ្រើសរើសជាតំណាង |

| | |
|---|---|
| | មានចំនួន ដ៏ច្រើន(២៥%) ឆ្លើយថា *"មិនដឹង"* លើសំណួរថា តើគេអនុវត្តមាត្រដ្ឋាន អន្តរជាតិពាក់ព័ន្ធទៅនឹងបញ្ហា រើសអើងយេនឌ័រ និងហិង្សាផ្លូវភេទក្នុងជម្លោះដែរទេ។ ចំនួននេះ ប្រហែលអាចមកពីមុខតំណែងរបស់អ្នក ផ្តល់ចម្លើយធ្វើការនៅក្នុង អ.វ.ត.ក (ការិយាល័យរដ្ឋបាល និងផ្នែកសេវាទូទៅ)។ តែយ៉ាងណាក្តី ក៏មានចំនួនច្រើនលើសលុបដល់ទៅ (៧១%) ទទួល *"យល់ស្រប"* ក្នុងកម្រិតខ្លះដោយយល់ថា មាត្រដ្ឋានទាំងនេះកំពុងត្រូវបានអនុវត្ត |
| **ឃ. គេត្រូវចាត់វិធានការគ្រប់គ្រាន់លុបបំបាត់ឧបសគ្គ ជាក់ស្តែងនានា ដែលស្ត្រីអាចប្រឈមក្នុងការស្វែងរក យុត្តិធម៌អន្តរកាល** | **លទ្ធផល** |
| ៤. ឧបសគ្គរបស់ស្ត្រីក្នុងការចូលរួមនៅក្នុង អ.វ.ត.ក ត្រូវបានដោះស្រាយតាមរយៈការផ្តល់ឲ្យមានការមើល ថែទាំកុមារ ការដឹកជញ្ជូនប្រកបដោយសុវត្ថិភាព និង ការបកប្រែភាសា។ | ចម្លើយសរុប: ៤៩<br>៥= យល់ស្របយ៉ាងខ្លាំង (២) (៤%)<br>៤= យល់ស្រប (១៦) (៣៣%)<br>៣= យល់ស្របបន្តិចបន្តួច (១២) (២៤%)<br>២ = មិនយល់ស្រប (៩) (១៨%)<br>១ = មិនយល់ស្របយ៉ាងខ្លាំង (៣) (៦%)<br>0 = ខ្ញុំមិនដឹង (៧) (១៤%)<br>គ្មានចម្លើយ (១)<br>ចំនួនភាគច្រើន (៦១%) នៃនិយោជិតដែលបាន ជ្រើសរើសជាតំណាង យល់ស្រប ទៅនឹងឧបសគ្គ របស់ស្ត្រីក្នុងការចូលរួមនៅក្នុង អ.វ.ត.ក ត្រូវបាន ដោះស្រាយ ដោយមានចំនួនស្មើតែមួយភាគបួន (២៥%)មិនយល់ស្របទៅនឹងឃ្លាខាងលើ ហើយ ចំនួន (១៤%) តិចជាងហ្នឹងឆ្លើយថា *"មិនដឹង"*។ |

| | |
|---|---|
| ៥. បុគ្គលិករបស់ អ.វ.ត.ក បង្ហាញពីសមត្ថភាព យល់ ដឹងយេនឌ័រក្នុងរាល់ការងារទាំងឡាយ ហើយពួកគេ ទទួលបានវគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់ ដើម្បីពង្រឹង ការយល់ដឹង និងវិធីសាស្ត្រ ឆ្លើយតបទៅនឹងបញ្ហាយេនឌ័រ | ចម្លើយសរុប: ៤៩<br>៥= យល់ស្របយ៉ាងខ្លាំង (៧) (១៤%)<br>៤= យល់ស្រប (១៦) (៣៣%)<br>៣= យល់ស្របបន្តិចបន្តួច (១០) (២០%)<br>២ = មិនយល់ស្រប (៨) (១៦%)<br>១ = មិនយល់ស្របយ៉ាងខ្លាំង (៨) (១៦%)<br>0 = ខ្ញុំមិនដឹង (៨) (១៦%)<br>គ្មានចម្លើយ (១)<br>ខណៈដែលមានអ្នកផ្តល់ចម្លើយចំនួន(៦៧%)យល់ស្របថា បុគ្គលិករបស់ អ.វ.ត.ក បង្ហាញពី សមត្ថភាពយល់ដឹងយេនឌ័រ ឯមួយភាគបី (៣២%) ឆ្លើយថា មិនយល់ស្រប។ សម្រាប់ចម្លើយ នេះ នៅត្រង់ *"ខ្ញុំមិនដឹង"* គេអាចចាត់ទុក ចម្លើយ មួយនេះថា ជាការបង្ហាញអំពីភាពខ្វះការយល់ដឹង ផ្នែកយេនឌ័រ ហើយបើសិនណាគេបន្ថែមទៅលើ ចំនួន *"មិនយល់ស្រប"* គេនឹងទទួលបានចំនួន ស្មើតែពាក់កណ្តាលនៃចម្លើយទាំងអស់(គឺមាន ៤៨%) |
| ៦. សាក្សីពាក់ព័ន្ធនឹង បទឧក្រិដ្ឋផ្លូវភេទ និងបទឧក្រិដ្ឋដែលផ្អែកលើយេនឌ័រត្រូវបានគាំពារពីស្លាកស្នាមទុយ៌ស តាមរយៈការរក្សាការសម្ងាត់ និងសន្តិសុខ ដោយ រួមបញ្ចូលទាំងការបន្តឃ្លាំមើល ដើម្បីឆ្លើយទៅ នឹងតម្រូវការលើការគាំពារពីការគំរាមកំហែង ប្រើហិង្សា ឬទោសទណ្ឌផ្សេងៗទៀត | ចម្លើយសរុប: ៤៩<br>៥= យល់ស្របយ៉ាងខ្លាំង (៦) (១២%)<br>៤= យល់ស្រប (២៥) (៥១%)<br>៣= យល់ស្របបន្តិចបន្តួច (៦) (១២%)<br>២ = មិនយល់ស្រប (១) (២%)<br>១ = មិនយល់ស្របយ៉ាងខ្លាំង (0)<br>0 = ខ្ញុំមិនដឹង (១១) (២២%)<br>គ្មានចម្លើយ (១)<br>ក្នុងខណៈអ្នកឆ្លើយស្មើតែមួយភាគបួន (២២%) ឆ្លើយ |

| | |
|---|---|
| | ថា *"ខ្ញុំមិនដឹង"* គេអាចសន្មតថា ចំនួននេះ ទាក់ទិនទៅនឹងមុខងាររបស់អ្នកផ្តល់ចម្លើយ តែមានចំនួនដែលច្រើនលើសលុបដល់ទៅ(៧៥%)នៃចំនួនអ្នកតំណាងទាំងនោះបានឆ្លើយយល់ស្របថា សាក្សីដែលពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋផ្លូវភេទ និងបទឧក្រិដ្ឋដែលផ្អែកលើយេនឌ័រត្រូវបានគាំពារ។ |
| **ង. កិច្ចខិតខំប្រឹងប្រែងទាំងឡាយត្រូវបានធ្វើឡើងដើម្បីដោះស្រាយភាពលំអៀងយេនឌ័រនៅក្នុងស្ថាប័នផ្ទាល់ និងដើម្បីដោះស្រាយឥរិយាបទសង្គម ចំពោះការរើសអើង និងអសមភាពរបស់ ស្ត្រី** | **លទ្ធផល** |
| ៧. ស្ត្រីត្រូវបានតំណាងដោយមានចំនួនស្មើនឹងចំនួនបុរសលើរាល់ទិដ្ឋភាពនៅអ.វ.ត.ក [មានរួមបញ្ចូលទាំងអ្នកស៊ើបអង្កេត អ្នកធ្វើសេចក្តីថ្លែងការណ៍ អ្នកបកប្រែ បុគ្គលិករដ្ឋបាល និងបុគ្គលិកកម្មវិធី បុគ្គលិកផ្សព្វផ្សាយ។ល។] | ចម្លើយសរុប: ៤៩<br>៥= យល់ស្របយ៉ាងខ្លាំង (៨) (១៦%)<br>៤= យល់ស្រប (១០) (២០%)<br>៣= យល់ស្របបន្តិចបន្តួច (១០) (២០%)<br>២ = មិនយល់ស្រប (១៥) (២០%)<br>១ = មិនយល់ស្របយ៉ាងខ្លាំង (២) (១៨%)<br>0 = ខ្ញុំមិនដឹង (៤) (៨%)<br>គ្មានចម្លើយ (១)<br>ចម្លើយភាគច្រើន (៥៦%) យល់ស្របថា ស្ត្រី និងបុរសត្រូវបានតំណាងដោយមានចំនួនស្មើគ្នានឹងចំនួនបុរសក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃអ.វ.ត.ក តែមានចម្លើយមួយភាគបី (៣៤%) មិនយល់ស្រប។<br>សំណួរនេះជាការលើកឡើងសាឡើងវិញនៃសំណួរលេខ១។ ចូរកត់សម្គាល់ទៅលើភាពខុសគ្នានៃចម្លើយនានា ដោយភាគរយច្រើនលើសលុប (៨៨%) នៃនិយោជិតដែលជ្រើសរើសជាតំណាង ឆ្លើយថា ស្ត្រី និងបុរសដែលគេ |

| | |
|---|---|
| | ជ្រើសរើសជាតំណាង មានចំនួនស្មើគ្នា រួមបញ្ចូលទាំងកម្រិតនៃការធ្វើការសម្រេចនៅគ្រប់ទិដ្ឋភាពទាំងអស់របស់អ.វ.ត.ក។ |
| ៨. អ.វ.ត.ក ប្រកាស អនុវត្ត និងកត់ត្រារាល់សកម្មភាពនៃគោលការណ៍ដាក់ពិន័យ និង យន្តការបណ្តឹងលើផ្នែកបៀតបៀនផ្លូវភេទនៅតាមកន្លែងធ្វើការ | ចម្លើយសរុប: ៤៩<br>៥= យល់ស្របយ៉ាងខ្លាំង (៧) (១៤%)<br>៤= យល់ស្រប (១៤) (២៩%)<br>៣= យល់ស្របបន្តិចបន្តួច (៩) (១៨%)<br>២ = មិនយល់ស្រប (២) (៤%)<br>១ = មិនយល់ស្របយ៉ាងខ្លាំង (២) (៤%)<br>0 = ខ្ញុំមិនដឹង (១៥) (៣0%)<br>គ្មានចម្លើយ (១)<br>ក្នុងខណៈអ្នកផ្តល់ចម្លើយភាគច្រើន(៦0%) យល់ស្របថា គេបង្កើតការ *"ការមិនអត់ឱន"* ចំពោះការបៀតបៀនផ្លូវភេទនៅតាមកន្លែងធ្វើការ ក៏មានចំនួនមួយភាគបី (៣0%) ឆ្លើយថា *"មិនដឹង"* នេះបញ្ជាក់ថា *"និយោជិតមិនដឹង"* អំពីគោលការណ៍នោះឡើយ ហើយបូកផ្សំចំនួនអ្នកផ្តល់ចម្លើយមិនយល់ស្របចំពោះគោលការណ៍បៀតបៀនផ្លូវភេទដែលចូលជាធរមាន ចំនួននេះកើនឡើង៣៨% |
| ៩. អ.វ.ត.ក មានគោលការណ៍ជ្រើសរើសបុគ្គលិកដោយវិជ្ជមាន និងខិតខំបង្កើនចំនួនបុគ្គលិកស្ត្រី | ចម្លើយសរុប: ៤៩<br>៥= យល់ស្របយ៉ាងខ្លាំង (២) (៤%)<br>៤= យល់ស្រប (២៤) (៤៩%)<br>៣= យល់ស្របបន្តិចបន្តួច (១២) (២៤%)<br>២ = មិនយល់ស្រប (២) (៤%)<br>១ = មិនយល់ស្របយ៉ាងខ្លាំង (0)<br>0 = ខ្ញុំមិនដឹង (៩) (១៨%) |

| | |
|---|---|
| | គ្មានចម្លើយ (១)<br>គួរឲ្យចាប់អារម្មណ៍ដែរ អ្នកផ្តល់ចម្លើយលើសលុបមានចំនួន (៧៧%) បានយល់ស្របដោយយល់ថា អ.វ.ត.ក មានគោលការណ៍ជ្រើសរើសបុគ្គលិកដោយភាពវិជ្ជមាន ទោះបីជាមិនមានគោលការណ៍ ឬ ក៏មិនមានការខិតខំ ដែលគេបង្កើតជាប្រព័ន្ធបែបនេះកើតឡើងក៏ដោយ។<br>ការយល់ឃើញលើសកម្មភាពវិជ្ជមាន ដែលមានស្រាប់នេះអាច ចេញមកពីការខិតខំប្រឹងប្រែង របស់បុគ្គល ឬ តាមផ្នែក និងអង្គភាពផ្សេងៗ ក្នុង អ.វ.ត.ក ។ |
| ១០. អ.វ.ត.ក មានគោលការណ៍សមភាពប្រាក់បៀវត្សរ៍ និងយន្តការបណ្តឹង | ចម្លើយសរុប: ៤៨<br>៥= យល់ស្របយ៉ាងខ្លាំង (១៤) (២៩%)<br>៤= យល់ស្រប (១៩) (៤០%)<br>៣= យល់ស្របបន្តិចបន្តួច (៥) (១០%)<br>២ = មិនយល់ស្រប (៣) (៦%)<br>១ = មិនយល់ស្របយ៉ាងខ្លាំង (១) (២%)<br>0 = ខ្ញុំមិនដឹង (៦) (១២.៥%)<br>គ្មានចម្លើយ (២)<br>និយោជិតដែលជ្រើសរើសជាតំណាងភាគច្រើន(៧៩%) យល់ស្របថាអ.វ.ត.កមានគោលការណ៍សមភាពប្រាក់បៀវត្សរ៍។<br>តាមការកត់សម្គាល់ទៅលើវិធីសាស្ត្រ គេដកសំណួរនេះចេញពីតារាងសំណួរសម្ភាសន៍ដោយសារអ.វ.ត.ក បានបង្កើតកម្រិតប្រាក់បៀវត្សរ៍ទៀងទាត់ឲ្យនិយោជិត។<br>យោងតាមចម្លើយបានបញ្ជាក់ថា ទោះបីហាក់ដូចជាមិនមានភាពភាន់ច្រឡំក្នុងសំណួរអំពីភាពខុសគ្នាលើប្រាក់បៀវត្សរ៍រវាង បុគ្គលិកជាតិ និងបុគ្គលិកអន្តរជាតិ |

| | |
|---|---|
| | ក៏ដោយ ក៏សំណួរអាច បញ្ជាក់ពីអសមភាពប្រាក់បៀវត្សរ៍របស់បុរស និងស្ត្រី ផងដែរ |
| ១១. អ.វ.ត.ក ផ្តល់ឱកាសឲ្យបុគ្គលិកស្ត្រីដើម្បីអភិវឌ្ឍជំនាញក្នុងទម្រង់ជាការបង្រៀន ការហ្វឹកហ្វឺនឯកទេស និងការរៀបចំការទំនាក់ ទំនងគ្នា។ | ចម្លើយសរុប: ៤៩<br>៥= យល់ស្របយ៉ាងខ្លាំង (៥) (១០%)<br>៤= យល់ស្រប (២៨) (៥៧%)<br>៣= យល់ស្របបន្តិចបន្តួច (១១) (២២%)<br>២ = មិនយល់ស្រប (៣) (៦%)<br>១ = មិនយល់ស្របយ៉ាងខ្លាំង (០)<br>០ = ខ្ញុំមិនដឹង (២) (៤%)<br>គ្មានចម្លើយ (១)<br>ដូចនៅក្នុងសំណួរលេខ៩ដែរ លទ្ធផលដែលគួរឲ្យចាប់អារម្មណ៍នៅត្រង់មូលដ្ឋាន[នៃការសិក្សា] រកឃើញថា មិនមានភស្តុតាងបញ្ជាក់ថាមានគោលការណ៍របស់ អ.វ .ត.ក ដែលបង្កើតឡើង ឬ ការអនុវត្ត ណាមួយ ដើម្បីផ្តល់ឱកាសឲ្យស្ត្រីអភិវឌ្ឍជំនាញវិជ្ជាជីវៈនោះឡើយ។ តែយ៉ាងណាក្តី ចំនួនអ្នកឆ្លើយភាគច្រើន(៨៩%) បាន យល់ស្របថាក្នុងកម្រិតមួយថា ឱកាសទាំងនេះត្រូវបានផ្តល់ឲ្យស្ត្រីដែលធ្វើការនៅក្នុងអ.វ.ត.ក ទៅវិញ ។ ឧទាហរណ៍ ដូច នៅក្នុងសំណួរលេខ៩ អាចបញ្ជាក់អំពីកិច្ចខិតខំក្រៅផ្លូវការ និងការខិតខំមិនអចិន្ត្រៃយ៍នានានៅតាមអង្គភាព និងតាមផ្នែកផ្សេងៗ ។ |

## សង្ខេបលទ្ធផលនៃការរកឃើញទូទៅ

1. ជាទូទៅ និយោជិតរបស់ អ.វ.ត.ក យល់ឃើញថា តំណាងបុរស និងស្ត្រីមានចំនួនស្មើគ្នាក្នុងអ.វ.ត.ក ដោយរួមបញ្ចូលទាំងកម្រិតនៃការធ្វើសេចក្តីសម្រេចផងដែរ ក៏ប៉ុន្តែ ចំនួនដែលឆ្លើយថា យល់ស្រប បែរជា ធ្លាក់ចុះយ៉ាងខ្លាំង ចាប់ពីសំណួរលេខ១ (មានចំនួន៨៨%រាយការណ៍ថាយល់ស្រប) រហូត

ដល់សំណួរលេខ៧ (មាន៥៦%យល់ស្រប និង៣៤%ឆ្លើយថាមិនយល់ស្រប)។ លទ្ធផលចម្លើយរបស់ និយោជិតមិនស៊ី គ្នាទៅនឹងជំរឿនពិតប្រាកដនៃនិយោជិតជាស្ត្រីនៅក្នុង អ.វ.ត.ក នោះទេ។

2. ចំនួនលើសលុបរបស់អ្នកផ្តល់ចម្លើយដល់ទៅ ៩០% យល់ស្របថា ក្រុមអ្នកចូលរួមស្ត្រី និងដៃគូរមានឥទ្ធិពលក្នុងការរៀបចំ ការអនុវត្ត ការឃ្លាំមើល និងការវាយតម្លៃកម្មវិធីនានារបស់ អ.វ.ត.ក ទោះបីជាចំនួននៃការយល់ស្របធ្លាក់ចុះដល់ទៅ ៦១% នៅពេលមានការវាយតម្លៃលើឧបសគ្គនៃការចូលរួមរបស់ស្ត្រីនៅក្នុង អ.វ.ត.ក យ៉ាងណាក្តី ។ ផ្ទុយទៅវិញ ៧៥% ឆ្លើយយល់ស្របចំពោះសំណួរដែលថា សាក្សីពាក់ព័ន្ធនឹង បទឧក្រិដ្ឋផ្លូវភេទ និងបទឧក្រិដ្ឋផ្អែកលើយេនឌ័រទទួលបានការគាំពារ ហើយ ៧១% ឆ្លើយយល់ស្របថា មាត្រដ្ឋានអន្តរជាតិពាក់ព័ន្ធទៅនឹងបញ្ហា រើសអើងយេនឌ័រ និង ហិង្សាផ្លូវភេទក្នុងស្ថានភាពមានជម្លោះ កំពុងត្រូវបានអនុវត្តនៅក្នុងអ.វ.ត.ក។ តាមឧទាហរណ៍ទាំងពីរនេះ មានចំនួនអ្នកផ្តល់ចម្លើយជា ច្រើនរាយការណ៍ថា *"ខ្ញុំមិនដឹង"* (រវាងពី ២០% ទៅ ២៤%) នេះអាចបញ្ជាក់អំពីចំនួនខ្ពស់ជាង នៃបុគ្គលិកមិនមែនជាអ្នកបច្ចេកទេស ដែលបានចូលរួមនៅក្នុង ការស្ទង់មតិនេះដែរ។

3. ចម្លើយចំពោះសំណួរពាក់ព័ន្ធទៅនឹងការយល់ដឹងអំពីយេនឌ័រ ផ្នែកជំនាញ និងគោលការណ៍ [សំណួរលេខ៥ លេខ៨ លេខ៩ និងលេខ១១] ពិតជាទាញចំណាប់អារម្មណ៍ពិសេស។ ក្នុងខណៈ៦៧% ឆ្លើយយល់ស្របថា មានជំនាញយេនឌ័រ និងមានវគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់ ក៏នៅមានចំនួន៣២% ទៀតបែរជា *ឆ្លើយថាមិនយល់ស្រប* ហើយ ១៦% *ឆ្លើយថាមិនដឹង* ។ គេអាចវិភាគលើចម្លើយ *"ខ្ញុំមិនដឹង"* ថាជាការបង្ហាញពីភាពខ្វះការយល់ដឹងអំពីយេនឌ័រ បើកាលណាគេបូកផ្សំចំនួនអ្នកផ្តល់ចម្លើយថា *មិនយល់ស្រប* លើសំណួរដដែលទៀតនោះ ចំនួនបូកផ្សំនេះកើនឡើងស្មើតែពាក់កណ្តាល (៤៨%) នៃបុគ្គលិក អ.វ.ត.ក ដោយពួកគេមិនយល់ស្រប ឬ មិនដឹងថា មានវត្តមានសមត្ថភាពយេនឌ័រនៅតាមមុខងារនានាក្នុង អ.វ.ត.ក ឬ យ៉ាងណា ។

4. ជាងនេះទៅទៀត អ្នកផ្តល់ចម្លើយចំនួន ៧៧% យល់ស្របថា គេមានគោលការណ៍វិធានការវិជ្ជមាននៅក្នុង អ.វ.ត.ក ប៉ុន្តែ តាមពិត គោលការណ៍ជាផ្លូវការបែបនេះមិនដែលមានសោះឡើយ។ តាមករណីស្រដៀងគ្នានេះដែរ អ្នកផ្តល់ចម្លើយចំនួន ៨៩% យល់ស្របថា និយោជិតស្ត្រីនៃ អ.វ.ត.ក មានឱកាស

អភិវឌ្ឍជំនាញ ទោះបីជាមិនមានកម្មវិធីនៃការបង្រៀនបង្កើតឡើងជាប្រព័ន្ធយ៉ាងនេះក៏ដោយ។ យោងតាមករណីទាំងពីរនេះ *ចម្លើយយល់ស្របក្នុងកម្រិតខ្ពស់* ទទួលបានពីអ្នកផ្តល់ចម្លើយ អាចសរបញ្ជាក់ឲ្យឃើញពីការខិតខំប្រឹងប្រែងនៅតាមផ្នែក និងនៅតាមអង្គភាពនៅក្នុង អ.វ.ត.ក ធ្វើឡើងសម្រាប់ពង្រឹង និង រក្សាទុកបុគ្គលិកជាស្ត្រី។

5. ជាចុងក្រោយ អ្នកផ្តល់ចម្លើយចំនួន៦០% បានឆ្លើយយល់ស្របថា គោលការណ៍បៀតបៀនផ្លូវភេទរបស់អ.វ.ត.ក ពិតជាមានមែន ហើយនៅជាធរមាន។ ទោះយ៉ាងណាក្តី អ្នកផ្តល់ចម្លើយ៣០% បានរាយការណ៍ថា *"ខ្ញុំមិនដឹង"* ដែលនេះបង្ហាញថា យ៉ាងតិចណាស់ បុគ្គលិកចំនួនមួយភាគបី "មិនបានដឹង" អំពីគោលការណ៍ និងយន្តការបណ្តឹងរបស់អ.វ.ត.ក ហើយបើសិនណាគេបន្ថែមចំនួននៃចម្លើយមិនយល់ស្របទៀតនោះ ចំនួនបុគ្គលិកកើនឡើងដល់ទៅ៣៨%។ គួរកត់សម្គាល់ដែរថា ក្នុងអំឡុងពេលនៃការសិក្សាមូលដ្ឋានេះ ផ្នែកអង្គការសហប្រជាជាតិបានផ្សព្វផ្សាយគោលការណ៍នៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទទៅដល់បុគ្គលិកតុលាការខ្មែរក្រហមផ្នែកអង្គការសហប្រជាជាតិទាំងអស់គ្នា។ គេមិនច្បាស់ទេថា គោលការណ៍នេះត្រូវបានផ្សព្វផ្សាយដល់បុគ្គលិកជាតិនៃ អ.វ.ត.ក ឬយ៉ាងណានោះទេ។ នៅក្នុងកិច្ចសន្ទនាជាបុគ្គលិកអន្តរជាតិ ពួកគេជាច្រើននាក់បានយល់ខុសទៅលើ គោលការណ៍ការពារមិនឲ្យមានបៀតបៀនផ្លូវភេទ។